**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អ្នកនាំពាក្យ គ.ជ.ប**
លេខ : ០៧២ គ.ជ.ប

ថ្ងៃ អាទិត្យ ៤រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## បញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៣ ត្រូវបានប្រកាសផ្សព្វផ្សាយ

នាព្រឹកថ្ងៃអាទិត្យ ទី៣១ ខែធ្នូ ឆ្នាំ២០២៣ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សោម សូរីដា** សមាជិក គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំ ដើម្បីផ្សព្វផ្សាយអំពីការផ្ដល់សុពលភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៣។

**ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ អំពីខ្លឹមសារមួយចំនួនទាក់ទងនឹងការផ្ដល់សុពភាព និងការប្រកាសផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៣ ដែលក្នុងនោះ មានកិច្ចដំណើរការជាទូទៅនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ និងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ ការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោត ការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ រយៈពេល ១៩ថ្ងៃ ការរៀបចំបញ្ជីបោះឆ្នោតដំបូង ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង និងបញ្ជីបោះឆ្នោតផ្លូវការ។

អំពីកិច្ចដំណើរការជាទូទៅនិងកិច្ចសហប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ **ឯកឧត្តមសោមសូរីដា** មានប្រសាសន៍ថា មានគណបក្សនយោបាយ ចំនួន ២ គឺគណបក្សប្រជាជនកម្ពុជា និងគណបក្សហ្វ៊ុនស៊ិនប៉ិច បានដាក់ភ្នាក់ងារសង្កេតមើលដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតសរុបចំនួន **៣.៨២៩**រូប ក្នុងនោះ មានស្ត្រីចំនួន **១.១០៨**រូប និងមានសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ៣ គឺ សហភាពសហព័ន្ធយុវជនកម្ពុជា គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល) និងសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍សម្រាប់ខេត្តសៀមរាប បានដាក់អ្នកសង្កេតការណ៍របស់ខ្លួន សរុបចំនួន **២.៣១៨**រូប ក្នុងនោះ មានស្ត្រីចំនួន ៨៨៧រូប។ **ឯកឧត្តម** បានបន្តថា ដើម្បីធានាឱ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ គ.ជ.ប បានសហការជាមួយគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការ



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល៖ info@nec.gov.kh

បោះឆ្នោត ហៅកាត់ថា គ.ស.អ ដាក់ចេញនូវសេចក្តីណែនាំរួមលេខ ០៣ សណន ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០២៣ ស្តីពីកិច្ចសហការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣។

អំពីការស្រង់ស្ថិតិប្រជាពលរដ្ឋប៉ាន់ស្មាន ការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោត **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា ដើម្បីរៀបចំបញ្ជីបោះឆ្នោតមួយដែលធានាបាននូវភាពពេញលេញ ត្រឹមត្រូវ និងមានបច្ចុប្បន្នភាព ក្រសួងមហាផ្ទៃ និង គ.ជ.ប បានចេញសេចក្តីណែនាំរួមលេខ ០១៩ សណន ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២១ ស្តីពីការរៀបចំត្រៀមការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ។

អំពីការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា គ.ជ.ប បានអនុវត្តការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការឆ្នាំ២០២២ នៅតាមភូមិ ដោយចាប់ផ្តើមពីថ្ងៃទី១ ដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៣។ លទ្ធផលនៃការចែកនោះបានចំនួន **៩.១២៤.៧៦៨សន្លឹក** ស្មើនឹង **៩៣,៩៧%** នៃលិខិតអញ្ជើញ សរុបចំនួន **៩.៧១០.៦៥៥សន្លឹក**។

អំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ រយៈពេល ១៩ថ្ងៃ **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា គ.ជ.ប បានតែងតាំងក្រុមចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ ចំនួន **១.៦៥២ក្រុម** រួមជាមួយគ្រូ ២រូប ប្រចាំ ក្រុង ស្រុក ខណ្ឌ។ **ឯកឧត្តម** បន្តថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ បានចាប់ផ្តើមធ្វើនៅគ្រប់ឃុំ សង្កាត់ទូទាំងប្រទេស នៅថ្ងៃទី១ ដល់ថ្ងៃទី១៩ ខែតុលា ឆ្នាំ២០២៣។ ការិយាល័យចុះឈ្មោះបោះឆ្នោតបើកធ្វើការជារៀងរាល់ថ្ងៃ ទាំងថ្ងៃសៅរ៍ ទាំងថ្ងៃអាទិត្យ ពេលព្រឹកចាប់ពីម៉ោង ៧:០០ ដល់ម៉ោង ១១:៣០នាទីថ្ងៃត្រង់ និងពេលរសៀលចាប់ពីម៉ោង១៤:០០ដល់ម៉ោង១៧:៣០នាទីល្ងាច។ ក្នុងរយៈពេល ១៩ថ្ងៃ នៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ នៅតាមឃុំ សង្កាត់ ទទួលបានលទ្ធផលដូចតទៅ៖

- អ្នកមកសុំចុះឈ្មោះបោះឆ្នោតថ្មី មានចំនួន **២៣៣.៧៧២នាក់** ក្នុងនោះ ស្ត្រីមានចំនួន **១១១.៧១៥នាក់**
- អ្នកដែលត្រូវបានលុបចេញពីបញ្ជីបោះឆ្នោត មានចំនួន **១២០.៨៨៣នាក់**
- អ្នកដែលបានផ្ទេរចូលក្នុងឃុំ សង្កាត់ថ្មី មានចំនួន **៩៧.៩៥៨នាក់**
- អ្នកមកសុំកែតម្រូវឈ្មោះ ឬ/និងទិន្នន័យក្នុងបញ្ជីបោះឆ្នោត មានចំនួន **១៨.៦៦៨នាក់**។

អំពីការរៀបចំបញ្ជីបោះឆ្នោតដំបូង **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា គ.ជ.ប បានធ្វើការផ្ទៀងផ្ទាត់ ជាប្រចាំនូវទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតដែលទទួលបានតាមថ្ងៃនីមួយៗជាមួយនឹងទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតដែលទទួលបានកន្លងមក។ បន្ទាប់ពីបញ្ចប់ការចុះឈ្មោះបោះឆ្នោត ការប្តឹងតវ៉ាទៅនឹងការបដិសេធការចុះឈ្មោះ ត្រូវបានដោះស្រាយរួចរាល់ ហើយទិន្នន័យ



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល៖ info@nec.gov.kh

ត្រូវបានបញ្ជូន និងទទួលរួចរាល់ គ.ជ.ប ត្រូវផ្ទៀងផ្ទាត់ទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត បន្ទាប់មក គ.ជ.ប ធ្វើការពិនិត្យសម្រេចមុននឹងបិទផ្សាយជាសាធារណៈ។

ចំពោះការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ការដាក់ ការទទួល និងការដោះស្រាយពាក្យបណ្ដឹង **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួច គ.ជ.ប បានបោះពុម្ព និងចាត់ឱ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត តាមឃុំ សង្កាត់នីមួយៗ ហើយបញ្ជីបោះឆ្នោតដំបូងត្រូវបានបង្ហោះនៅលើគេហទំព័ររបស់ គ.ជ.ប (voterlist.nec.gov.kh)។ ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង មានរយៈពេលប្រាំថ្ងៃ ដោយត្រូវចាប់ផ្ដើមពីថ្ងៃទី២៤ ខែវិច្ឆិកា ដល់ថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២៣ (កាលបរិច្ឆេទនេះត្រូវសម្រាក ៣ថ្ងៃ ដោយសារចំថ្ងៃពិធីបុណ្យជាតិ)។ **ឯកឧត្តម** បានបន្តថា ក្នុងដំណាក់កាលបិទផ្សាយបញ្ជីបោះឆ្នោតដំបូង និងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោត នៅថ្នាក់ក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេស បានទទួលពាក្យបណ្ដឹងសរុបចំនួន ៩បណ្ដឹង ក្នុងនោះ មានបណ្ដឹងតវ៉ាចំនួន ១បណ្ដឹង និងបណ្ដឹងជំទាស់ចំនួន ៨បណ្ដឹង។ បណ្ដឹងទាំង ៩ ត្រូវបានក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចយល់ព្រម ដោយក្នុងនោះមានការលុបឈ្មោះបន្ថែមចំនួន ៨នាក់ និងរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតវិញចំនួន ១នាក់។

ជាចុងក្រោយ **ឯកឧត្តម សោម សូរីដា** មានប្រសាសន៍ថា បន្ទាប់ពីបណ្ដឹងតវ៉ា និងបណ្ដឹងជំទាស់ត្រូវបានដោះស្រាយរួចរាល់ជាស្ថាពរ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ នេះ គ.ជ.ប បានសម្រេចផ្ដល់សុពលភាពជាផ្លូវការលើបញ្ជីបោះឆ្នោត ឆ្នាំ២០២៣ ដែលមានទិន្នន័យ ដូចខាងក្រោម៖

- ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើង ចំនួន **១០.៩៧៨.២៥៨នាក់** ក្នុងនោះស្ត្រី **៥.៦៦០.៧៣៧នាក់**
- ចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោត ឆ្នាំ២០២៣ **៩.៨៧១.៤៩៥នាក់** ក្នុងនោះស្ត្រី **៥.២៤០.៩៧៩នាក់** ស្មើនឹង **៨៩,៩២%** នៃប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើងសរុប
- ការិយាល័យបោះឆ្នោតចំនួន **២៤.០៣៤ការិយាល័យ** បើប្រៀបធៀបនឹងឆ្នាំ២០២២ មានការកើនឡើងចំនួន **២៤៥ការិយាល័យ។**

បន្ទាប់មក មានសំណួររបស់ភាគីចូលរួមក្នុងកិច្ចប្រជុំ បានលើកឡើងថា ហេតុអ្វី ក៏តួលេខចំនួនស្ត្រីដាក់នៅក្នុងវង់ក្រចក?

គ.ជ.ប បានបញ្ជាក់ជូនថា គ.ជ.ប បានរំលេចតួលេខក្នុងវង់ក្រចកដូចនេះ ចង់បង្ហាញថា ចំនួនស្ត្រីចូលរួមក្នុងការបោះឆ្នោតច្រើនជាងបុរស។

មានសំណួរមួយទៀត សួរថា នៅពេលដែលប្រជាពលរដ្ឋបានទៅចុះឈ្មោះបោះឆ្នោត តើគាត់មានឯកសារគ្រប់ដែរ ឬទេ ?

គ.ជ.ប បានបញ្ជាក់ជូនថា ឆ្នាំ២០២៣ នេះ មានជាង ១០.០០០ករណី បានទៅចុះឈ្មោះបោះឆ្នោតដោយខ្វះលក្ខខណ្ឌ។ ក្នុងនោះជាង ៤.០០០នាក់ អត់គ្រប់អាយុ ១៨ឆ្នាំ។ ចំនួនជាង ៤.០០០នាក់ ទៀត



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

ខ្វះឯកសារ គឺអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ហើយអ្នកមួយចំនួនទៀតអត់មានឯកសារអ្វីទាំងអស់។ នៅពេលនោះក្រុមចុះឈ្មោះបោះឆ្នោត បានណែនាំពួកគាត់ឱ្យទៅធ្វើឯកសារបញ្ជាក់អត្តសញ្ញាណ និងធ្វើតាមនីតិវិធីនៃការចុះឈ្មោះបោះឆ្នោត។

នេះជាកិច្ចប្រជុំលើកចុងក្រោយជាមួយភាគីពាក់ព័ន្ធ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៣ ដែលសមាសភាពចូលរួមមកពីក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងព័ត៌មាន អគ្គស្នងការដ្ឋាននគរបាលជាតិ តំណាងគណបក្សនយោបាយ តំណាងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអ្នកសារព័ត៌មាន ចំនួនជិត ៤០នាក់។



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ 012 959 666 / 092 105 556 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh